ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ...

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី ការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ២០១៨ និងការទទួលយកសំណើស្រាវជ្រាវសម្រាប់

សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ លើកទី៥ របស់ធនាគារជាតិនៃកម្ពុជា ក្រោមប្រធានបទ
"ការពង្រីកប្រភពកំណើនសេដ្ឋកិច្ចកម្ពុជា"

៙៙៙*៚៚៚

ស្ថិតក្នុងស្ថានភាពអំណោយផលពីសុខសន្តិភាព ស្ថិរភាពនយោបាយ និងការបើកទូលាយសេដ្ឋកិច្ច កម្ពុជាទទួលបានកំណើនជាមធ្យមលើសពី ៧% ក្នុងមួយឆ្នាំ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ ហើយអតិផរណាបន្តមានកម្រិតទាបអាចគ្រប់គ្រងបាន គួបផ្សំនឹងស្ថានភាពទូទាត់អន្តរជាតិមាននិរន្តរភាព។ បច្ចុប្បន្ន កម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ដោយចំណូលក្នុងមនុស្សម្នាក់ បានកើនប្រមាណ ៥ដង ពី ២៥០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០មក ដល់ ១.៤២៣ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៧។

កំណើនសេដ្ឋកិច្ចរឹងមាំគួបផ្សំនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បានរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជាជាលំដាប់។ ចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រខ្លាំង (១,៩ដុល្លារអាមេរិក/១ថ្ងៃ) បានថយចុះយ៉ាងឆាប់រហ័សដល់ ២,២% នៅឆ្នាំ២០១២ ដែលជាអត្រាទាបជាងប្រទេសអាស៊ានមួយចំនួនដែលមានចំណូលខ្ពស់ជាងកម្ពុជា ដូចជាប្រទេសឥណ្ឌូណេស៊ី, ឡាវ, ហ្វីលីពីន និងវៀតណាម។

ទោះយ៉ាងណា កម្ពុជានៅធ្វើដំណើរដ៏វែងឆ្ងាយថែមទៀតក្នុងការបន្តនាំមកនូវភាពរុងរឿងប្រកបដោយចីរភាពជូនប្រជាជន។ ក្នុងស្ថានភាពនេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងពង្រីកប្រភពកំណើនដែលមានមូលដ្ឋានតូចនៅឡើយ តាមរយៈការប្រើប្រាស់សក្តានុពលគ្រប់វិស័យ ផលិតផលថ្មីៗ និងការពង្រឹងសមត្ថភាពជំនាញ។ ក្នុងគោលដៅរួមចំណែកបង្កើនការស្រាវជ្រាវលើបញ្ហាទាំងនេះ ធនាគារជាតិនៃកម្ពុជាបានកំណត់យកប្រធានបទសម្រាប់សន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៥ប្រចាំឆ្នាំ២០១៨ ស្តីពី "ការពង្រីកប្រភពកំណើនសេដ្ឋកិច្ចកម្ពុជា" ដែលគ្រោងនឹងប្រព្រឹត្តទៅនៅដើមខែធ្នូ ឆ្នាំ២០១៨ ខាងមុខ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ , ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

អត្ថបទស្រាវជ្រាវសម្រាប់ចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទនេះមាន ៥ ប្រធានបទ៖

(i) ការជំរុញវិស័យកសិកម្ម (កំណត់កត្តាដែលរាំងស្ទះដល់វិស័យនេះក្នុងការប្រែក្លាយពីកសិកម្មបែបវិបុលកម្មទៅជាកសិកម្មបែបអតិផល ព្រមទាំងបង្ហាញពីជម្រើសគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហានេះ)

(ii) ការពង្រីកមូលដ្ឋានការនាំចេញ រួមមាន ផលិតផលនិងទីផ្សារ (ពិនិត្យលើនិន្នាការថ្មីៗក្នុងការធ្វើពិពិធកម្មការនាំចេញ រួមទាំងឧត្តមភាពនៃផលិតផលនិងទិសដៅនាំចេញ, វាយតម្លៃលើផលិតផលនិងទីផ្សារដែលមានសក្តានុពលសម្រាប់ធ្វើពិពិធកម្មការនាំចេញនាពេលអនាគត និងពិចារណាលើគំនិតផ្តួចផ្តើមគោលនយោបាយក្នុងស្រុក ដែលអាចទាញយកសក្តានុពលនោះបាន)

(iii) ការធ្វើសមាហរណកម្មជាមួយបណ្តាញផលិតកម្ម និងខ្សែសង្វាក់នៃការផ្គត់ផ្គង់នៅក្នុងតំបន់ (ពិនិត្យស្ថានភាពថ្មីៗនៃការចូលរួមរបស់កម្ពុជាក្នុងបណ្តាញផលិតកម្មនិងខ្សែសង្វាក់នៃការផ្គត់ផ្គង់នៅក្នុងតំបន់នៃ "រោងចក្រអាស៊ី", សិក្សាកត្តាចម្បងៗដែលបង្អាក់ដល់ការធ្វើសមាហរណកម្មឱ្យកាន់តែស៊ីជម្រៅរបស់កម្ពុជាទៅក្នុងរោងចក្រអាស៊ី និងពិចារណាលើវិធានការជាយុទ្ធសាស្ត្រដែលអាចដោះស្រាយបញ្ហាទាំងនេះ

(iv) ការប្រើប្រាស់សក្តានុពលទេសចរណ៍ (សិក្សាសក្តានុពលវិស័យទេសចរណ៍ដើម្បីរួមចំណែកគាំទ្រកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍ និងកំណត់ជម្រើសគោលនយោបាយក្នុងការប្រើប្រាស់សក្តានុពលទាំងនោះ រួមមាន ការធ្វើឱ្យមានកំណើនរឹងមាំក្នុងវិស័យទេសចរណ៍សំដៅផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ក្នុងស្រុក) និង

(v) ការរៀបចំកម្លាំងពលកម្មសម្រាប់ពេលអនាគត (ដោយសារការកើនឡើងនៃការប្រើប្រាស់បញ្ញាសិប្បនិម្មិត និងស្វ័យប្រវត្តិកម្ម ការងារជាច្រើននាពេលបច្ចុប្បន្នអាចបាត់បង់ ខណៈការងារថ្មីៗដែលត្រូវការជំនាញផ្សេងៗគ្នានឹងលេចឡើង ដែលតម្រូវឱ្យប្រព័ន្ធអប់រំនិងការបណ្តុះបណ្តាលត្រូវមានភាពបត់បែន ដើម្បីឱ្យយុវជនអាចទទួលបានជំនាញដែលមានតម្រូវការនាពេលអនាគត។ តើកម្ពុជាអាចប៉ាន់ស្មានពីការប្រែប្រួលតម្រូវការជំនាញ និងការពង្រឹងប្រព័ន្ធអប់រំនិងការបណ្តុះបណ្តាលបច្ចេកទេស ដើម្បីត្រៀមកម្លាំងពលកម្មសម្រាប់ពេលអនាគតដោយរបៀបណា?

បេក្ខជនដែលមានចំណាប់អារម្មណ៍ក្នុងការស្រាវជ្រាវប្រធានបទណាមួយក្នុងចំណោម៥ខាងលើ សូមផ្ញើប្រវត្តិរូបសង្ខេប និងជម្រើសប្រធានបទមកអគ្គនាយកដ្ឋានបច្ចេកទេសឱ្យបានត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។ ធនាគារជាតិនៃកម្ពុជានឹងជ្រើសរើសយកអត្ថបទស្រាវជ្រាវដែលមានគុណវុឌ្ឍិ ដើម្បីមកធ្វើបទបង្ហាញនៅក្នុងសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៥ សម្រាប់ឆ្នាំ២០១៨ ខាងមុខនេះ ហើយនឹងផ្តល់រង្វាន់លើកទឹកចិត្តជូនម្ចាស់អត្ថបទស្រាវជ្រាវដែលទទួលបានជ័យលាភី ព្រមទាំងបោះផ្សាយអត្ថបទស្រាវជ្រាវលើគេហទំព័រនិងព្រឹត្តិបត្រត្រីមាសរបស់ធនាគារជាតិនៃកម្ពុជា។

**អគ្គនាយកដ្ឋានបច្ចេកទេស**

**ជា សិរី**

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
អគ្គនាយកដ្ឋានបច្ចេកទេស
ទូរស័ព្ទ៖ ០១៧ ៣៧ ៥២ ៦៥ / ០៨៥ ៨៨៨ ២៣៤
អ៊ីម៉ែល៖ macroconfer@nbc.org.kh